និយ័តករគណនេយ្យនិងសវនកម្ម

Accounting and Auditing Regulator

# ក្របខណ្ឌកាត់បន្ថយ ការរាយការណ៍ហិរញ្ញវត្ថុកម្ពុជា

# Cambodian Reduced Financial Reporting Framework

ការលើកលែងការទទួលស្គាល់ ការវាស់វែង និងការលាតត្រដាង
ផ្អែកតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ
នៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម
( CIFRS for SMEs )

សម្រាប់សហគ្រាស/អង្គភាពរាយការណ៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
( Qualifying Entity )

© រក្សាសិទ្ធិគ្រប់យ៉ាង ឆ្នាំ២០២៥ - និយ័តករគណនេយ្យនិងសវនកម្ម

# គោលបំណង

១. គោលបំណងនៃក្របខណ្ឌកាត់បន្ថយការរាយការណ៍ហិរញ្ញវត្ថុកម្ពុជានេះ គឺដើម្បី បញ្ជាក់ពីការទទួលស្គាល់, ការវាស់វែង, និងការលើកលែងការលាតត្រដាងសម្រាប់ របាយការណ៍-ហិរញ្ញវត្ថុរបស់សហគ្រាស/អង្គភាព ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Qualifying Entity) និងបានចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ក្របខណ្ឌនេះនឹងកាត់បន្ថយបន្ទុកអនុលោមភាព ដោយរក្សាបាននូវគុណភាព, ភាពពាក់ព័ន្ធ, និងតម្លាភាពនៃព័ត៌មានហិរញ្ញវត្ថុដើម្បី ផ្តល់ជូនអ្នកប្រើប្រាស់។ ក្របខណ្ឌនេះត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយការទទួលស្គាល់ ការវាស់វែង និងការលាតត្រដាង ដែលសមាមាត្រទៅនឹងទំហំ ភាពស្មុគស្មាញ និងតម្រូវការរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៃសហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្របតាមគោលការណ៍គ្រឹះនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs )។

# វិសាលភាព

៣. ក្របខណ្ឌនេះអាចអនុវត្តបានចំពោះ **របាយការណ៍ហិរញ្ញវត្ថុដែលមិនរងសវនកម្មឯករាជ្យ** របស់សហគ្រាស/អង្គភាព ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Qualifying Entity)។ សហគ្រាស/អង្គភាព ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិសាលភាពនៃក្របខណ្ឌនេះត្រូវបានកំណត់ថាជាសហគ្រាស/អង្គភាពដែលមិនតម្រូវឱ្យដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ និងជាសហគ្រាស/អង្គភាព ដែលមិនមានការទទួលខុសត្រូវជាសាធារណៈ។

៤. ក្របខណ្ឌនេះមិនអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុរួម (Consolidated Financial Statements) នោះទេ។

# គោលការណ៍សម្រាប់ការលើកលែងនៃការទទួលស្គាល់ ការវាស់វែង និងការលាតត្រដាង

៥. ដើម្បីកំណត់អំពីការលើកលែងនៃការទទួលស្គាល់ ការវាស់វែង និងការលាតត្រដាងណាមួយ សម្រាប់ សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវពិចារណាគោល-ការណ៍មានដូចខាងក្រោម៖

ក). **ភាពពាក់ព័ន្ធ៖** ពិចារណាលើលក្ខខណ្ឌចាំបាច់ក្នុងការទទួលស្គាល់ ការវាស់វែង និងការលាតត្រដាង ដើម្បីផ្តល់នូវព័ត៌មានហិរញ្ញវត្ថុដែលមានសារៈប្រយោជន៍ និងមានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ។

ខ). **គុណសម្បត្តិ និងគុណវិបត្តិ៖** ពិចារណាអំពីគុណសម្បត្តិនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមក្របខណ្ឌនេះ មានអត្ថប្រយោជន៍ច្រើនសម្រាប់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ។

៦. ក្របខណ្ឌនេះផ្តល់នូវការលើកលែងជាក់លាក់មួយចំនួនពីលក្ខខណ្ឌ នៃការទទួលស្គាល់ ការវាស់វែង និងការលាតត្រដាងដែលស្មុគស្មាញ ដើម្បីបន្ធូរបន្ថយបន្ទុកក្នុងការរាយការណ៍របស់ សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលរួមមានដូចខាងក្រោម៖

ក). **គណនេយ្យនៃតម្លៃសមស្រប** Fair Value Accounting**៖** សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានលើកលែងពីលក្ខខណ្ឌចាំបាច់ក្នុងការវាស់វែងទ្រព្យសកម្មតាមវិធីសាស្ត្រតម្លៃសមស្រប។

ខ). **ពន្ធពន្យារ** Deferred Tax **៖** សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានលើកលែងពីការទទួលស្គាល់បំណុល និងទ្រព្យសកម្មពន្ធពន្យារ។

គ). **ឧបករណ៍ហិរញ្ញវត្ថុ** Financial Instruments**៖** សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានលើកលែងពីការអនុវត្តលក្ខខណ្ឌចាំបាច់នៃការវាស់វែងតម្លៃសមស្រប សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមិនត្រូវបានធ្វើពាណិជ្ជកម្មនៅលើទីផ្សារជាសាធារណៈ ឬថ្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុមិនអាចរកបាននៅលើទីផ្សារ។

ឃ). **ភតិសន្យាហិរញ្ញវត្ថុ** Finance Lease**៖** សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចទទួលស្គាល់ភតិសន្យាទាំងអស់ជាភតិ-សន្យាប្រតិបត្តិការ។

ង). **អត្ថប្រយោជន៍និយោជិតរយៈពេលវែង Long-Term Employee Benefits៖** សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុញ្ញាតឱ្យប្រើវិធីសាស្ត្រសាមញ្ញសម្រាប់ការទទួលស្គាល់ អត្ថប្រយោជន៍ និយោជិតរយៈពេលវែងនោះ ជាផែនការវិភាគទានដែលបានកំណត់, ដែលកាតព្វកិច្ចរបស់និយោជកត្រូវបានកម្រិតត្រឹមតែជាវិភាគទានថេរ ដោយទទួលស្គាល់ជាចំណាយនៅពេលដល់កំណត់ដែលត្រូវបង់ ដោយមិនតម្រូវឱ្យទទួលស្គាល់ការសន្មតការគណនាតាមស្ថិតិ ឬកាតព្វកិច្ចនាពេលអនាគត។

ច). **ការថយចុះតម្លៃនៃទ្រព្យសកម្ម Impairment of Assets៖** សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុញ្ញាតឱ្យប្រើថ្លៃដើមប្រវត្តិសាស្ត្រ ដករំលស់ ដោយមិនបាច់ធ្វើការវាយតម្លៃលើការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្ម។

# សេចក្ដីថ្លែងការណ៍ អនុលោមភាពតាមក្របខណ្ឌ

៧. នៅពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំដោយអនុលោមតាមក្របខណ្ឌនេះ សហគ្រាស/អង្គភាពត្រូវបញ្ចូលសេចក្ដីថ្លែងការណ៍មួយនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញថា៖

**"របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ និងដាក់បង្ហាញដោយអនុលោមតាមក្របខណ្ឌកាត់បន្ថយការរាយការណ៍ហិរញ្ញវត្ថុកម្ពុជា "**

៨. នៅពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ មិនអនុលោមតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs ) សហគ្រាស/អង្គភាពមិនត្រូវបញ្ចូលសេចក្ដីថ្លែងការណ៍អំពីអនុលោមភាពដូចមាន ចែងក្នុងកថាខណ្ឌ ៣.៣ នៃ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម នោះទេ។

# សមាសធាតុនៃរបាយការណ៍ហិរញ្ញវត្ថុ

៩. អនុលោមតាមក្របខណ្ឌនេះ របាយការណ៍លំហូរសាច់ប្រាក់ និងរបាយការណ៍បម្រែបម្រួលមូលធន ត្រូវបានលើកលែង។ សហគ្រាស/អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលអនុវត្តក្របខណ្ឌនេះគឺតម្រូវឱ្យរៀបចំរបាយការណ៍ហិរញ្ញវត្ថុដូចខាងក្រោមៈ

ក). **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**
ខ). **របាយការណ៍ចំណូលពេញលេញ និងចំណេញរក្សាទុក**
គ). កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។

# លក្ខខណ្ឌចាំបាច់នៃការលាតត្រដាង

១០. អនុលោមតាមក្របខណ្ឌនេះ ការលាតត្រដាងក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម លើកលែងមិនអាចអនុវត្តបាន ឬមិនពាក់ព័ន្ធៈ

ក). ព័ត៌មានទូទៅ
ខ). សេចក្ដីថ្លែងការណ៍អនុលោមភាពតាមក្របខណ្ឌ
គ). គោលនយោបាយគណនេយ្យសំខាន់ៗ
ឃ). ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍
ង). ការលាតត្រដាងព័ត៌មានរបស់ភាគីពាក់ព័ន្ធ
ច). ទ្រព្យ រោងចក្រ និងបរិក្ខារ
ឆ). គណនីពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងទៀត
ជ). សាច់ប្រាក់ និងសាច់ប្រាក់សមមូល
ឈ). គណនីពាណិជ្ជកម្ម និងគណនីត្រូវសងផ្សេងទៀត
ញ). ប្រាក់កម្ចី
ត). ចំណូល
ថ). ចំណូល និងចំណាយហិរញ្ញវត្ថុ
ទ). មូលធនភាគហ៊ុន
ធ). សន្និធិ
ន). ទ្រព្យសកម្មអរូបី
ប). ទ្រព្យសកម្មជីវសាស្ត្រ (សម្រាប់សហគ្រាស/អង្គភាពមានសកម្មភាពកសិកម្ម)
ផ). ទ្រព្យវិនិយោគ។

# បទប្បញ្ញត្តិអន្តរកាល

១១. សហគ្រាស/អង្គភាព ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលអនុវត្តក្របខណ្ឌនេះ លើកដំបូង មិនតម្រូវឱ្យដាក់បង្ហាញព័ត៌មានប្រៀបធៀបក្នុងឆ្នាំដំបូងនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

១២. សហគ្រាស/អង្គភាព ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនតម្រូវឱ្យលាតត្រដាងអំពីផលប៉ះពាល់ជា បរិមាណនៃការកែតម្រូវទាំងអស់ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការអនុវត្តលើកដំបូងនោះទេ។

# ការត្រួតពិនិត្យក្របខណ្ឌប្រចាំឆ្នាំ

១៣. និយ័តករគណនេយ្យនិងសវនកម្ម អាចត្រួតពិនិត្យក្របខណ្ឌនេះជាប្រចាំឆ្នាំ ដើម្បីធានាប្រសិទ្ធភាព និងភាពពាក់ព័ន្ធនៃក្របខណ្ឌនេះ។ រាល់វិសោធនកម្មដែលកើតចេញពីការត្រួតពិនិត្យនេះ នឹងត្រូវធ្វើឡើងក្នុងដំណើរការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីធានាថាមតិយោបល់របស់ភាគីពាក់ព័ន្ធត្រូវបានយកមកពិចារណា។

# សង្គតិភាពជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឌីជីថល

១៤. ក្របខណ្ឌនេះ ត្រូវបានរៀបចំឡើងដើម្បីធានានូវសង្គតិភាព ជាមួយនឹង **ថ្នាលរៀបចំរាយការណ៍ហិរញ្ញវត្ថុឌីជីថល របស់និយ័តករគណនេយ្យនិងសវនកម្ម** ដើម្បីជួយសម្រួលដល់ ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុក្នុងទម្រង់ឌីជីថល។ សហគ្រាស/អង្គភាពត្រូវបានលើកទឹកចិត្តឱ្យដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុក្នុងទម្រង់ឌីជីថល ដើម្បីទទួលបានអត្ថប្រយោជន៍ពីប្រសិទ្ធភាព និងលក្ខណៈអន្តរប្រតិបត្តិការនៃថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល។